# ១.សេចក្តីផ្តើម

គោលការណ៍ណែនាំអំពីវិធីសាស្ត្រក្នុងការកំណត់ទីតាំង និង ការអនុវត្តកម្មវិធីដាំដើមឈើគឺជាឯកសារ គាំទ្រការកសាងគោលនយោបាយវិស័យគ្រាប់ពូជឈើនៅកម្ពុជា។ ដំណើការរៀបចំចងក្រងគោលការណ៍ណែនាំនេះបានប្រកាន់យកនូវការពិគ្រោះយោបល់ជាមូលដ្ឋាន ដែលត្រូវបានដឹកនាំដោយរដ្ឋបាលព្រៃឈើ និង គំរោងគ្រាប់ពូជឈើកម្ពុជាដោយមានការគាំទ្រផ្នែកថវិកាពីស្ថានទូតរាជរដ្ឋាភិបាលដាណឺម៉ាក្សប្រចាំរាជធានីភ្នំពេញ ។

កំណែទម្រង់វិស័យព្រៃឈើដែលកំពុងប្រព្រឹត្តទៅនៅក្នុងប្រទេសកម្ពុជា បានផ្តល់អាទិភាពជាចំបងដល់កម្មវិធីដាំដើមឈើ។ ក្នុងជំហានតំបូង រដ្ឋបាលព្រៃឈើ តាមរយៈគំរោងគ្រាប់ពូជឈើកម្ពុជាបានបង្កើតតំបន់ប្រភពគ្រាប់ពូជឈើបានមួយចំនួននៅទូទាំងប្រទេសក្នុងគោលបំណងធានានូវការផ្គត់ផ្គង់គ្រាប់ពូជឈើដែលមានគុណភាពល្អដល់កម្មវិធីដាំដើមឈើនានា។ ជំហានបន្ទមកទៀតគឺត្រូវកំណត់ទីតាំងដែលត្រូវដាំឈើឱ្យបានសមស្រប ធ្វើយ៉ាងណាដើម្បីឱ្យការងារដាំឈើបំពេញបាន នូវកម្មវត្ថុសំខាន់ៗទាំងបីគឺ ការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការការពារបរិស្ថាន។

ឯកសារដែលកំពុងបង្ហាញជូននេះមានគោលបំណងផ្តល់ជំនួយដល់រដ្ឋបាលព្រៃឈើក្នុងការរៀបចំផែនការដាំឈើ ដោយបានផ្តល់នូវការតម្រង់ទិសក្នុងការកំណត់តំបន់អាទិភាពដែលត្រូវដាំឈើ។ ផ្អែកលើការកំណត់ទីតាំងជាបឋមដោយប្រើប្រាស់ផែនទី លក្ខណៈវិនិច្ឆ័យតំបូងៗត្រូវបានកំណត់និងវាយតម្លៃដោយផ្អែកលើសន្ទស្សន៍នានា ក្នុងគោលបំណងជ្រើសរើសទីតាំងដែលត្រូវដាំឈើឱ្យសមស្របទៅនឹងកម្មវត្ថុណាមួយក្នុងចំណោមកម្មវត្ថុខាងលើ ហើយក្នុងពេលជាមួយគ្នានោះក៏តំរូវឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍នៅមូលដ្ឋានផងដែរ។ ទោះជាយ៉ាងណាក៏ដោយ គោលនយោបាយគាំទ្រ គោលការណ៍ច្បាប់និងសេដ្ឋកិច្ចនៅទន់ខ្សោយនៅឡើយហើយទាមទារឱ្យមានការរៀបចំនិងអនុវត្តន៍ដោយគ្រប់ស្ថាប័នរបស់រដ្ឋាភិបាលដែលពាក់ព័ន្ធ។

ឯកសារនេះត្រូវបានបង្ហាញជូនជាពីរផ្នែកគឺ:

១. ការកំណត់ទីតាំងដែលត្រូវដាំដើមឈើ

២. ការអនុវត្តការងារដាំដើមឈើ